# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១២៨៤ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃ សៅរ៍ ២ រោច ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃ ចន្ទ ១២រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃ ចន្ទ ៤ កើត ខែ បុស្ស ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០២២ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២៣ | ឥណទាន មុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មី ក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | <u>ការផ្ទេរចេញ</u> | | | | <u>3.139.700</u> | |
| | ជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) | | | | 3.139.700 | |
| 69 | ចំណាយមិនបានគ្រោងទុក | 1.713.847.000 | 1.648.203.300 | - | 3.139.700 | 1.645.063.600 |
| | <u>ការផ្ទេរចូល</u> | | | <u>3.139.700</u> | | |
| | ១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | 370.700 | | |
| 60 | ការទិញ | 74.366.400 | 74.366.400 | 12.000 | - | 74.378.400 |
| 61 | សេវាកម្ម | 55.934.300 | 55.934.300 | 358.700 | - | 56.293.000 |
| | ១៧-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | | 618.000 | | |
| 61 | សេវាកម្ម | 37.144.000 | 37.144.000 | 618.000 | - | 37.762.000 |
| | ៣២-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | 2.151.000 | | |
| 65 | ឧបត្ថម្ភធន | 17.137.000 | 17.137.000 | 2.151.000 | - | 19.288.000 |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

១)- ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំនួន ៣៧០,៧ លានរៀល ក្នុងនោះ សម្រាប់ចំណាយមិនមែនបន្ទុកបុគ្គលិកលើការអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តការសិក្សា និងវាយតម្លៃប្រសិទ្ធភាពនៃការប្រើប្រាស់អគ្គិសនីក្នុងវិស័យសុខាភិបាលចំនួន ២៨០ លានរៀល និងសម្រាប់ទូទាត់ចំណាយបេសកកម្មក្រៅប្រទេសក្នុងឆ្នាំ ២០២២ ចំនួន ៩០,៧ លានរៀល។

២)- ផ្តល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ៦១៨ លានរៀល សម្រាប់ចំណាយលើការពឹងពាក់មេធាវីក្នុងដំណើរការការពារក្តីពាក់ព័ន្ធនឹងផលប្រយោជន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (សំណុំរឿងករណីការឃាត់ខ្លួនលោក ត្រី ម៉ះផល ប្រធាននាយកដ្ឋានសត្វព្រៃ និងជីវៈចម្រុះ នៃរដ្ឋបាលព្រៃឈើ)។

៣)- ផ្ដល់ជូនក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំនួន ២ ១៥១ លានរៀល សម្រាប់បង្គ្រប់បង់វិភាគទានជូនកម្មវិធីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) ឆ្នាំ ២០២៣ ក្នុងនោះ÷ (១)-វិភាគទានកម្មវិធីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC), (២)-វិភាគទានអង្គការអន្តរជាតិខាងការងារ (ILO), (៣)-វិភាគទានសមាជិក Colombo Process។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ